**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១៤៣២ សជណ

ថ្ងៃ ពុធ ១១ កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៣

**ជម្រាបមក**
**លោក សុត ផ្លាយចាំម ប្រធានអង្គការមជ្ឈមណ្ឌល**
**សិក្សាបណ្ដុះបណ្ដាលកសាងសន្តិភាព និងដោះស្រាយទំនាស់ (CPCS)**

**កម្មវត្ថុ** ៖ ករណីកិច្ចប្រជុំស្ដីពី "Review of Current Humanitarian Efforts, and Seeking Effective Ways Forward" នៅខេត្តសៀមរាប ដែលរៀបចំដោយអង្គការមជ្ឈមណ្ឌលសិក្សាបណ្ដុះបណ្ដាលកសាងសន្តិភាព និងដោះស្រាយទំនាស់ (**CPCS**)។

**យោង** ៖ - រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ៣១៤សជណ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ៤៦២៣ កបទ.សអ.អប១ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងមហាផ្ទៃតម្រូវឱ្យអង្គការមជ្ឈមណ្ឌលសិក្សាបណ្ដុះបណ្ដាលកសាងសន្តិភាព និងដោះស្រាយទំនាស់ (**CPCS**) បញ្ឈប់ជាបន្ទាន់នូវកិច្ចប្រជុំស្ដីពី"Review of Current Humanitarian Efforts, and Seeking Effective Ways Forward" ដែលប្រព្រឹត្តទៅនៅថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៣ នៅខេត្តសៀមរាប ដោយសារសកម្មភាពនេះអាចជាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់រដ្ឋសមាជិកអាស៊ាន ដែលផ្ទុយនឹងធម្មនុញ្ញអាស៊ាន ច្បាប់ស្ដីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងលក្ខន្តិកៈដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។ ក្នុងករណីមិនអនុវត្តតាមស្មារតី នៃលិខិតនេះ ក្រសួងមហាផ្ទៃនឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូមលោកប្រធាន អនុវត្តតាមស្មារតី នៃលិខិតនេះដោយការទទួលខុសត្រូវ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុន.ហុន**

**ចម្លងជូន៖**
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌

"ដើម្បីជូនជ្រាប"

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- រដ្ឋបាលខេត្តសៀមរាប

"ដើម្បីមុខការ"

- ឯកសារ - កាលប្បវត្តិ

ទីស្ដីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh